**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៩៥
ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០
**សាលដីកា**
លេខៈ១៤២
ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ............. ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

-លោកស្រី ...............

**តំណាងមហាអយ្យការ**

-លោក ................ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧៩៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកាឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥៦ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះគផ ភេទប្រុសអាយុ ៣៤ឆ្នាំ ជាតិ ខ្មែរមុខរបរជាងទង ទីលំនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះគឹម ធុន(រ) ម្តាយឈ្មោះហ៊ូ ស៊ុត(រ) ប្រពន្ធឈ្មោះសសមានកូន០២ នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះសសភេទស្រីអាយុ ៣៣ឆ្នាំ ជាតិខ្មែរមុខរបរ ស៊ីឈ្នួលកាត់ដេរ មានទីលំនៅផ្ទះលេខ៩៣ ផ្លូវលេខ១៧២ សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ ហង្ស ស៊ីម (ស) ម្តាយឈ្មោះឃី យ៉ាន (ស) ប្តីឈ្មោះគផ មានកូន០២ នាក់ ។

**កម្មវត្ថុបណ្តឹង** ប្តីសុំផ្តាច់សមគ្គសង្វាសពីប្តី

បានឃើញបណ្តឹងសាទុក្ខលេខ៥៤៥ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩៩ របស់ឈ្មោះគវណ ជាអ្នកទទួលសិទ្ធិពីធផបានប្តឹងមិនសុខចិត្ត នឹងសេចក្តីសម្រេចនៃសាលដីកាលេខ៧៩៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី២៣ខែកុម្ភៈឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៨-០១-៩៩ របស់ឈ្មោះសសបានប្តឹងសុំផ្តាច់សមគ្គសង្វាស ពីឈ្មោះគផ ដោយសំអាងហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះនេះ តាំងពីឆ្នាំ១៩៨៩ រហូតដល់ឆ្នាំ១៩៩៥ ខ្លួនមានផ្ទៃពោះកូនទី២ បាន៨ខែកន្លះ ស្រាប់តែប្តីខ្លួនចុះចោលផ្ទះរហូតដល់សព្វថ្ងៃ គាត់មានប្រពន្ធមួយទៀត ជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាជាមួយឈ្មោះគផ នេះតទៅ ។

តាមចម្លើយឈ្មោះសសបានឆ្លើយបញ្ជាក់ថា ខ្លួនបានរៀបការជាមួយឈ្មោះគផ កាលពីថ្ងៃទី២២-០៤-១៩៨៩ ។ ក្នុងពេលរៀបការ និងរួមរស់ជាមួយគ្នា ក្នុងនាមប្តីប្រពន្ធរហូតដល់ឆ្នាំ១៩៩៥ខ្លួនក៏មានទំងន់កូនទី២បាន៨ខែកខ្លះប្តីខ្លួនបានចុះចោលផ្ទះទៅមានប្រពន្ធមួយទៀត រហូតដល់សព្វថ្ងៃ ។ ព្វថ្ងៃខ្លួនមានកូន០២នាក់ ១-ឈ្មោះ ស៊ីម សេរីវ័ត្ន ភេទស្រីអាយុ៧ឆ្នាំ ២_ឈ្មោះ ស៊ីម វាសនា ភេទប្រុសអាយុ៥ឆ្នាំ ហើយមានទ្រព្យសម្បត្តិរួម ដីទំហំ១៣,៥ម×៦,៥ម ស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ មានព្រំប្រទល់ខាងជើងទល់ផ្លូវ ខាងលិចទល់ព្រំដី ង៉ែត គន្ធា ខាងត្បូងទល់ព្រំដីណិប ជឿន និងខាងកើតទល់ព្រំដី លី យ៉ុង ។

ដីនេះខ្លួនទិញ ៦តម្លឹង ៥ជី គឺខ្លួនខ្ចីលុយម្តាយ ២តម្លឹងផង ។

សព្វថ្ងៃនេះ ខ្លួននៅជំពាក់បំណុលគេ៣.០០០ដុល្លារ (បីពាន់ដុល្លារ) ដោយខ្លួនខ្ចីគេ ចំណាយក្នុងការឆ្លងទន្លេ និងព្យាបាលកូនត្រូវគ្រាក់ទ័រ ។

ដីនេះមានតម្លៃ៣.០០០ដុល្លារ និងសំណូមពរ សុំសិទ្ធិគ្រប់គ្រងកូនទាំង០២នាក់ និងដីទំហំ១៣,៥ម×៦,៥ម ចំពោះអាហារកិច្ចខ្លួនមិនប្តឹងទាមទារទេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៦(ច) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី២៨-០១-១៩៩៩ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងដើម្បាប់ ។

២. ឱ្យនារីឈ្មោះសសនិងឈ្មោះគផ ផ្តាច់សមគ្គសង្វាសពីគ្នា ចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមការព្រមព្រៀងរបស់គូភាគី ដោយដាក់កំហុសទៅលើឈ្មោះគផ។

៣. ឱ្យនារីឈ្មោះសសស្ថិតក្នុងភាពមេម៉ាយចំនួន៣០០ថ្ងៃ ចាប់តាំងពីថ្ងៃនេះតទៅ ។

៩. ប្រគល់កូនទាំងពីរនាក់ឈ្មោះស៊ីម សេរីវ័ត្ន ភេទស្រី អាយុ៧ឆ្នាំ ឈ្មោះ ស៊ីម វាសនា ភេទប្រុសអាយុ ៥ឆ្នាំ ឱ្យទៅឈ្មោះសសគ្រប់គ្រងចិញ្ចឹមបីបាច់ ចាប់តាំងពីថ្ងៃនេះតទៅ ។

មាតាបីតាដែលលែងលះគ្នា ត្រូវបំពេញសិទ្ធិ និងករណីកិច្ចអប់រំ ថែទាំចិញ្ចឹមកូនតាម មាត្រា៧៤ ៧៥ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៥. ដីទំហំ១៣,៥ម×៦,៥ម ដែលមានបង្កាន់ដៃលេខ២១០៦០ ចុះថ្ងៃទី០២-០៦-១៩៩៤ ស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យត្រូវប្រគល់ឱ្យឈ្មោះសសសម្រាប់បែងចែកសងបំណុលគេ និងដោះស្រាយចិញ្ចឹមកូនទាំង២ ចាប់ពីថ្ងៃនេះតទៅ ។

៦- បង្គាប់ឱ្យឈ្មោះសសបង់ប្រាក់ប្រដាប់ក្ដី៧០០០រៀល តាមការស្ម័គ្រចិត្តគឺ ពន្ធចុះបញ្ជី និងពន្ធហ្នឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល និងរង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០រៀល ។

៧- សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគីសម្រេចបើកផ្លូវប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លខ២០(ច) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៩ របស់លោកគផ បានប្ដឹងមិនសុខចិត្តនឹងសាលក្រមលេខ២៦(ច) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញលើសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៩៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៩ របស់ឈ្មោះគផ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទោស និងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២៦(ច) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល ។

៣. កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ ពីពន្ធចុះបញ្ជីក្ដី នឹងពន្ធហ្នឹងចំនួន២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ ចំណាយលើការប្រគល់ដីកាកោះចំនួន៥០០០៛ និងលើអាជ្ញាធរតុលាការចំនួន ៥០០០៛ សរុប១៣.០០០៛ ។

៥- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៥៤៥ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩៩ របស់ឈ្មោះគវណ ជាអ្នកទទួលសិទ្ធិពីគផ បានប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ៧៩៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសាលដីកាទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី២២-០៣-២០០០ របស់ឈ្មោះគផ

បានឃើញ សារណាតប ចុះថ្ងៃទី០៦-០៤-២០០០ របស់ឈ្មោះសស

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ចុះ ។

ក្រោយពីបានស្ដាប់ចម្លើយរបស់ឈ្មោះគផ ជាចុងចម្លើយ និងជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា: សាលាឧទ្ធរណ៍កាត់សេចក្ដីពុំត្រឹមត្រូវ កន្លងមកខ្លួនធ្លាប់បានឱ្យលុយកាកដល់កូនខ្លះៗដែរ តាមរយៈនាយកសាលា សូមសំណូមពរសុំសិទ្ធិគ្រប់គ្រងកូនទាំងពីរ និងសុំបែងចែកដី ជាពីរចំណែកស្មើគ្នា ព្រោះដីនេះជាទ្រព្យសម្បត្តិរួម ។

ក្រោយពីបានស្ដាប់ចម្លើយរបស់ឈ្មោះសសជាដើមចោទ និងជាចុងបណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា ខ្លួនមិនអាចឱ្យតាមសំណូមពរលោកគផ បានទេព្រោះដីនេះ ខ្លួនយកលុយពីម្ដាយខ្លួនមកទិញ ហើយឈ្មោះគផ ជាប្ដីបានចុះចោលខ្លួនទៅមានប្រពន្ធថ្មីជាង៥ឆ្នាំ ហើយ នៅពេលកូនខ្លួនមានជំងឺត្រូវគ្រាក់ទ័របុកនោះ គេពុំដែលមកសួរនាំ ឬ ជួយព្យាបាលកូនបន្តិចណាសោះ ឡើយ ខ្លួនបានខ្ចីលុយគេយកមកព្យាបាលកូនអស់ប្រហែល៣០០០ដុល្លាអាមេរិក ទាំងការទាំងដើម ។

សំណូមពរ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់គូក្ដី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៥៤៥ ចុះថ្ងៃទី១៣-១២-៩៩ របស់លោកគផ ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងរដ្ឋប្បវេណីនេះ មកជំនុំជំរះបានតាមមាត្រា១៥ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

យល់ឃើញថាលោកគផ បានចុះចោលប្រពន្ធ និងកូនទាំងពីរនាក់តាំពីឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ១៩៩៨បានទៅរៀបការប្រពន្ធថ្មីមួយទៀត ហើយពុំបានជួយឧបត្ថម្ភ និងព្យាបាលកូនមានរបួសដោយសារគ្រាក់ទ័របុកឱ្យរបួសនោះឡើយ ។

យល់ឃើញថា ការប្រគល់ជាសម្បត្តិរួមទៅឱ្យដើមចោទគ្រប់គ្រង ដើម្បីសងបំណុលគេ និងចិញ្ចឹមកូននោះ ជាការត្រឹមត្រូវទៅតាមមាត្រា៧០ វាក្យខណ្ឌទី៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧៩៦ ចុះថ្ងៃទី០៨-១១-៩៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីចំពោះមុខតួក្ដី**

១- ទទួលបណ្ដឹងសាទុក្ខលេខ៩៥៥ ចុះថ្ងៃទី១៣-១២-៩៩ របស់លោកគជ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្ដែបដិសេធដោយខុស នឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៧៩៦ ចុះថ្ងៃទី០៨-១១-៩៩ របស់សាលាឧទ្ធរណ៍ ទុកថាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្ដី ដែលលោកគជ បានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ ៖

ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្ដែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០០។